វិទ្យាស្ថានសភាកម្ពុជា
PARLIAMENTARY INSTITUTE OF CAMBODIA
STRENGTHENING PARLIAMENTARY CAPACITY

# ឯកសារស្រាវជ្រាវសង្ខេប

គណៈកម្មការទី១ ព្រឹទ្ធសភា

# ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ នៅក្នុងប្រទេសកម្ពុជា


| | | |
|---|---|---|
| ស្រាវជ្រាវដោយ ៖ | លោកស្រី **តុប ដាវី** | អ្នកបណ្តុះបណ្តាលផ្នែកស្រាវជ្រាវ |
| ផ្តល់ប្រឹក្សា៖ | លោក **សូ សុវណ្ណារិទ្ធិ** | អ្នកគ្រប់គ្រងផ្នែកស្រាវជ្រាវ |


ថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០១៩

# កំណត់សម្គាល់

វិទ្យាស្ថានសភាកម្ពុជា(វ.ស.ក) គឺជាស្ថាប័នឯករាជ្យមួយដែលផ្តល់ការគាំទ្រដល់សភាកម្ពុជា តាមរយៈការ ផ្តល់នូវឯកសារស្រាវជ្រាវតបតាមសំណើរបស់សមាជិក សមាជិកា និងគណៈកម្មការជំនាញរបស់រដ្ឋសភា ព្រឹទ្ធសភា ដែលមានការវិភាគទៅលើបញ្ហាដែលកំពុងតែកើតមាននៅពេលបច្ចុប្បន្ន និងដែលអាចនឹងកើតឡើងនាពេលអនាគតលើប្រធានបទការរៀបចំច្បាប់ និងគោលនយោបាយសាធារណៈ។ ឯកសារនេះផ្តល់នូវព័ត៌មានដែលពាក់ព័ន្ធនឹងការងារសភា និងការងារមណ្ឌល ឬភូមិភាគរបស់សមាជិក-សមាជិកាសភា ក៏ប៉ុន្តែរាល់អត្ថន័យដែលមាននៅក្នុងឯកសារទាំងនេះមិនមែនតំណាង ឬឆ្លុះបញ្ចាំងអំពីទស្សនៈផ្ទាល់របស់វិទ្យាស្ថានសភាកម្ពុជា សភា ឬសមាជិក-សមាជិកាណាម្នាក់នោះឡើយ ។

ខ្លឹមសារនៃឯកសារនេះមានកំណត់កាលបរិច្ឆេទច្បាស់លាស់ ដើម្បីផ្តល់ជាឯកសារជំនួយស្មារតីតបតាមម្ចាស់សំណើ ។ ឯកសារនេះមិនមានគោលបំណងផ្តល់ប្រឹក្សាផ្នែកច្បាប់ ឬគោលនយោបាយណាមួយឡើយ ដោយផ្តោតតែលើព័ត៌មានពីឯកសារដែលមានស្រាប់ និងមិនបានសិក្សាឲ្យ គ្រប់ជ្រុងជ្រោយដើម្បីឆ្លើយតបទៅនឹងបញ្ហាលម្អិតនៃការស្រាវជ្រាវសង្ខេបនោះទេ ពោលគឺដើម្បីឆ្លើយតបទៅនឹងសំណើដែលទទួលបានតែប៉ុណ្ណោះ។

ខ្លឹមសារនៃឯកសារស្រាវជ្រាវសង្ខេបនេះ ស្ថិតក្រោមច្បាប់ជាធរមានរបស់កម្ពុជា និងកិច្ចព្រមព្រៀងអន្តរជាតិស្តីពីសិទ្ធិអ្នកនិពន្ធ។ រាល់ការរៀបចំចងក្រងឡើងវិញដោយដកស្រង់នូវផ្នែកណាមួយ ឬខ្លឹមសារទាំងស្រុងនៃឯកសារស្រាវជ្រាវនេះត្រូវមានការអនុញ្ញាតពីវិទ្យាស្ថានសភាកម្ពុជា។

©រក្សាសិទ្ធិ ឆ្នាំ២០១៩ វិទ្យាស្ថានសភាកម្ពុជា (វ.ស.ក)។

# មាតិកា

១. សេចក្តីផ្តើម ........................................................................................................1

២. ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការជាជម្រើសមួយ

សម្រាប់ ដោះស្រាយ វិវាទក្រៅពីនីតិវិធីតុលាការ.....................................................................1

៣. យន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាក ............................................................ 2

៤. វិបាកនៃការអនុវត្ត ADR នៅខេត្តព្រះសីហនុ និងខេត្តកោះកុង.............................................. 4

៥. សេចក្តីសន្និដ្ឋាន .................................................................................................. 6

ឯកសារយោង........................................................................................................ 8

## តារាង និងឧបសម្ព័ន្ធ

តារាង ២០១៧ ករណីវិវាទតាមបណ្តាស្រុកនានាក្នុងខេត្តកោះកុង និងខេត្តព្រះសីហនុ ក្នុងឆ្នាំ ៖1.... 5

ឧបសម្ព័ន្ធ -២០០៦ ៖ វិវាទដីធ្លី តាមបណ្តាស្រុក នៅក្នុងខេត្ត កោះកុង និង ព្រះសីហនុ1២០១៧.... 7

## ១. សេចក្តីផ្តើម

ឯកសារស្រាវជ្រាវសង្ខេបនេះ បានរៀបចំឡើងដោយអ្នកបណ្តុះបណ្តាលរបស់វិទ្យាស្ថានសភាកម្ពុជា(វ.ស.ក) ដើម្បីឆ្លើយតបទៅនឹងសំណើរបស់គណៈកម្មការទី១ ព្រឹទ្ធសភា ឲ្យសិក្សាពីទិដ្ឋភាពទូទៅនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលារ(ADR)នៅក្នុងខេត្តព្រះសីហនុ និងកោះកុង។ ដើម្បីដោះស្រាយនូវសំណួរស្រាវជ្រាវខាងក្រោម ឯកសារស្រាវជ្រាវនេះធ្វើឡើងតាមរយៈការពិនិត្យមើលទិន្នន័យមានស្រាប់ ដែលអាចរកបានពីគេហទំព័រផ្លូវការរបស់រាជរដ្ឋាភិបាល និងអង្គការអន្តរជាតិ។

១). តើការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការមានន័យយ៉ាងដូចម្តេចនៅក្នុងប្រព័ន្ធតុលាការកម្ពុជា?
២). តើប្រព័ន្ធដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការសព្វថ្ងៃដំណើរការដូចម្តេចនៅក្នុងប្រទេសកម្ពុជា?

## ២. ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការជាជម្រើសមួយសម្រាប់ ដោះស្រាយវិវាទក្រៅពីនីតិវិធីតុលាការ

ការដោះស្រាយវិវាទទាំងឡាយណានៅក្រៅប្រព័ន្ធតុលាការ គឺត្រូវបានចាត់ទុកថាជាការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ(ADR)។ ការដោះស្រាយនេះត្រូវបានអនុវត្តដើម្បីឆ្លើយតបទៅនឹងការប្រើនីតិវិធីតុលាការដែលមានភាពស្មុគស្មាញ ដែលចំណាយពេលយូរ ចំណាយថវិកាច្រើន និងមានភាពតានតឹង។ ADR ត្រូវបានប្រើប្រាស់យ៉ាងទំលំទូលាយនៅក្នុងប្រទេសកម្ពុជា និងជាទូទៅត្រូវបានប្រើនៅក្នុងការដោះស្រាយវិវាទគ្រួសារ ដីធ្លី ធនធានធម្មជាតិ ការងារ និងពាណិជ្ជកម្មស៊ីវិល ព្រមទាំងករណីស៊ីវិលផ្សេងៗទៀត [1, 2]។ វិធីសាស្ត្រ ADR ត្រូវបានអនុវត្តន៍យ៉ាងទូលំទូលាយនៅក្នុងកម្មវិធីអភិវឌ្ឍធនធានធម្មជាតិសហគមន៍ដើម្បីដោះស្រាយនូវបញ្ហាដែលកើតមានឡើង [3]។ ADR កើតឡើងនៅពេលភាគីវិវាទយល់ព្រមជ្រើសរើសជម្រើសដ៏ល្អមួយសម្រាប់ការដោះស្រាយវិវាទដោយសន្តិវិធី ដោយមិនចាំបាច់ទៅដោះស្រាយនៅតុលាការ[2, 4, 5]។ ភាគីវិវាទអាចនឹងសម្រេចចិត្តទៅតុលាការដើម្បីដោះស្រាយវិវាទរបស់ពួកគេបន្ត បើសិនជាភាគីវិវាទមិនពេញចិត្តជាមួយនឹងដំណោះស្រាយដែលធ្វើឡើងតាមរយៈដំណើរការ ADR នេះ។ ដូច្នេះមានន័យថា ដំណើរការ ADR នេះមិនមែនជាជម្រើសចុងក្រោយរបស់ភាគីវិវាទនុះទេ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ADR គឺមានប្រសិទ្ធភាពច្រើនជាង ដោយហេតុចំណាយថវិកាទាបជាង លឿនជាង និងសង្គមទទួលស្គាល់ADRកាន់តែច្រើនឡើង។[4]។

## ៣. យន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

នៅក្នុងប្រទេសកម្ពុជា ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ មានយន្តការទូទៅចំនួនបួនសម្រាប់អនុវត្ត រួមមាន ការចរចា(negotiation) សន្ធានកម្ម (mediation) ការផ្សះផ្សា(conciliation) មជ្ឈតកម្ម (arbitration) [4, 6, 7]។

*ការចរចា* ត្រូវបានប្រើដោយភាគីវិវាទ ដើម្បីដោះស្រាយវិវាទដោយផ្ទាល់តាមរយៈការសម្របសម្រួល និងដោយគ្មានជំនួយពីភាគីទីបី។ នីតិវិធីនេះកើតឡើងនៅពេលដែលភាគីវិវាទទាំងពីរបានបង្កើតនូវដំណោះស្រាយតាមអ្វីដែលពួកគេចង់បាន ហើយព្យាយាមឈានដល់កិច្ចព្រមព្រៀងដែលភាគីទាំងពីរពេញចិត្ត។ នៅក្នុងគម្រោងដែលល្អបំផុត ភាគីវិវាទទាំងពីរសម្រេចយក**ការចរចា**ដោះស្រាយវិវាទ ដោយធ្វើកិច្ចព្រមព្រៀងរួមមួយ។ ដំណាក់កាលដំបូងនៃការចរចារដើម្បីឈានដល់ការបែកចែកទ្រព្យសម្បត្តិ ឬភាគហ៊ុន អាចប្រព្រឹត្តទៅដូចខាងក្រោម៖

- ភាគីនីមួយៗធ្វើបញ្ជីដែលខ្លួនចង់បាន (ដូចជា ផ្ទះ ទូក ឡាន ថវិកា ឬចំណែករួម)
- ភាគីនីមួយៗកំណត់នូវពេលវេលាណាមួយដើម្បីទទួលបានទ្រព្យសម្បត្តិ ឬភាគហ៊ុន និងព័ត៌មានលម្អិតផ្សេងទៀត
- ភាគីនីមួយៗមានជម្រើស សម្រាប់ការដោះស្រាយបែងចែកទ្រព្យសម្បត្តិ ឬភាគហ៊ុន ។

នៅពេលដែលបានព្រមព្រៀងគ្នាហើយ ភាគីវិវាទសរសេរលិខិតជាលាយលក្ខណ៍អក្សរដើម្បីបញ្ជាក់ពីល័ក្ខខ័ណ្ឌនៃទ្រព្យសម្បត្តិ ឬភាគហ៊ុន ដែលបានឯកភាព។ ឧទាហរណ៍ ច្បាប់ស្តីពីវិនិយោគនៅក្នុងប្រទេសកម្ពុជា មាត្រាទី ២០ បានអនុញ្ញាតឲ្យប្រើនីតិវិធីចរចារដើម្បីដោះស្រាយវិវាទ នៅពេលមានវិវាទវិនិយោគណាមួយកើតឡើង [8]។ ក្នុងឆ្នាំ ២០០៧ នៅប្រទេសកម្ពុជា ប្រហែល ៩២ ភាគរយ នៃក្រុមហ៊ុនអាជីវកម្ម បានប្រើនីតិវិធីចរចា ដើម្បីជាការដោះស្រាយវិវាទនៃដំណើរការអាជីវកម្ម[9]។

*សន្ធានកម្ម* គឺជាដំណើរការដោះស្រាយវិវាទរវាងភាគីវិវាទពីរ ឬច្រើន ដែលតម្រូវឲ្យមានភាគីទីបី គឺសន្ធានការី (អ្នកសម្រុះសម្រួល)ដែលមានអព្យាក្រឹត ដើម្បីជួយភាគីវិវាទពិភាក្សា និងរកដំណោះស្រាយដែលអាចទទួលយកបានពីគូរភាគីទាំងសងខាង [4, p. 81]។ រឿងរ៉ាវដែលលើកយកមកពិភាក្សាក្នុងដំណើរការសម្របសម្រួលនេះ គឺជាការសម្ងាត់ ហើយមិនអាចយកទៅធ្វើជាករណីប្តឹងជំទាស់ភាគីវិវាទម្ខាងទៀតបានទេ។ ដំណើរការដោះស្រាយវិវាទបែបនេះ មានភាពស្រដៀងគ្នាទៅនឹងដំណើរការផ្សះផ្សាដែលបានប្រើក្នុងតុលាការនៅប្រទេសកម្ពុជា (នីតិវិធីផ្សះផ្សារបស់តុលាការ) [4, p.85]។ ជាទូទៅនីតិវិធីនេះ កើតឡើងបន្ទាប់ពីភាគីវិវាទព្យាយាមចរចាគ្នា ប៉ុន្តែមិនអាចរកដំណោះស្រាយមួយបាន។ សម្រាប់សន្ធានកម្មដែលជោគជ័យ ជាទូទៅអនុវត្តដំណាក់កាលចំនួនប្រាំពីរ[4, p.104]។ ដំណាក់កាលទាំងនោះមានដូចជា ការផ្តួចផ្តើមសន្ធានកម្ម ការជ្រើសរើសសន្ធានការី ការផ្តល់ព័ត៌មានដល់សន្ធានការី ការបើកកិច្ចប្រជុំសម្រុះសម្រួល កិច្ចប្រជុំដោះស្រាយបញ្ហាទូទៅ ការប្រជុំជាឯកជន និងដំណាក់កាលបញ្ចប់សន្ធានកម្ម ។

*ការផ្សះផ្សា* គឺជានីតិវិធីខុសគ្នាពីសន្ធានកម្ម។ នៅក្នុងនីតិវិធីនេះ អ្នកផ្សះផ្សាជួបជាមួយភាគីវិវាទដោយឡែកពីគ្នា (ជាជាងជួបរួមគ្នាដូចនៅក្នុងសន្ធានកម្ម) ដើម្បីសុំឲ្យមានការលះបង់ចំណែកណាមួយទៅឲ្យភាគីវិវាទ

ម្ខាងទៀត[i]។ អ្វីដែលបានឯកភាពគ្នានេះ គឺមិនមែនជាកាតព្វកិច្ចតាមផ្លូវច្បាប់ទេ។ ដូចនឹងនីតិវិធីសន្ទានកម្ម ដែរ ដោយអាស្រ័យលើវិវាទ នីតិវិធីផ្សះផ្សាវិវាទនេះធ្វើឡើងក្រៅផ្លូវការដោយភាគីទីបីដូចជា ព្រះសង្ឃ អាចារ្យ អ្នកមានអំណាចដែលទុកចិត្តពីភាគីវិវាទ ឬព្រះមហាក្សត្រ(ជាគោលការណ៍) ហើយការផ្សះផ្សាជាផ្លូវការ ត្រូវបានធ្វើឡើងដោយមន្ត្រីរដ្ឋាភិបាល ដែលបានចាត់តាំងដោយ រដ្ឋាភិបាល និង/ ឬអង្គចៅក្រម។

នៅក្នុងប្រទេសកម្ពុជា ដំណើរការផ្សះផ្សាដោះស្រាយវិវាទ ធ្វើឡើងក្នុងជីវភាពប្រចាំថ្ងៃ ហើយប្រជាពលរដ្ឋមិនដែលគិតថាវិវាទទាំងនោះជាករណី «ព្រហ្មទណ្ឌ» ឬ ករណី «រដ្ឋប្បវេណី» ឡើយ។ ប្រជាជនតែងតែប្រើរបៀបដោះស្រាយវិវាទបែបផ្សះផ្សានេះ ប្រសិនបើវិវាទទាំងនោះមិនមានផលប៉ះពាល់ធ្ងន់ធ្ងរខ្លាំងដល់ជីវភាពរបស់ពួកគេ។ នីតិវិធីនេះ គឺបានអនុញ្ញាត និងមាននៅក្នុងច្បាប់ផ្សេងៗរួមមានច្បាប់ស្តីពី គ្រួសារ និង អាពាហ៍ពិពាហ៍ (វិវាទគ្រួសារ) ច្បាប់ការងារ (វិវាទការងារ) ច្បាប់ភូមិបាល និងបទបញ្ញត្តិ (វិវាទដីធ្លី) និង ក្រមនីតិវិធីរដ្ឋប្បវេណី ( បណ្តឹងរដ្ឋប្បវេណី)។

*មជ្ឈតកម្ម (អាជ្ញាកណ្តាល)* នីតិវិធីនេះគឺជាដំណើរការផ្លូវការនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ដែលភាគីវិវាទត្រូវដាក់ពាក្យបណ្តឹងទៅរដ្ឋបាលរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ឬមជ្ឈមណ្ឌលអាជ្ញាកណ្តាល [10]។ នៅក្នុងនីតិវិធីនេះ ភាគីដែលពាក់ព័ន្ធនឹងវិវាទ ជ្រើសរើសមជ្ឈត្តករម្នាក់ដែលពួកគេទុកចិត្ត( ឧ.ទ មាន ការអប់រំ និងបទពិសោធន៍វិជ្ជាជីវៈល្អ) សម្រាប់ការពិនិត្យភស្តុតាង និងការធ្វើសេចក្តីសម្រេចចិត្ត[4, p. 137] ។ សារៈប្រយោជន៍នៃនីតិវិធីនេះ គឺភាគីវិវាទជ្រើសរើសមជ្ឈត្តករដោយខ្លួនឯង និងចូលរួមក្នុងសវនាការជាផ្លូវការដែលគ្រប់ភាគីអាចបង្ហាញភស្តុតាងបាន [11]។

គូភាគីព្រមព្រៀងជាមុនដើម្បីគោរពតាមសេចក្តីសម្រេចរបស់អាជ្ញាកណ្តាលដែលយោងតាមច្បាប់ [4, p.137] ។ នៅពេលដំណើរការនៃនីតិវិធីមជ្ឈតកម្មត្រូវបញ្ចប់ មជ្ឈតករផ្តល់សេចក្តីសម្រេចជាលាយលក្ខណ៍អក្សរមួយ ដែលក្លាយជាកាតព្វកិច្ចដល់ភាគីវិវាទ។ សេចក្តីសម្រេចរបស់មជ្ឈតករមិនជាប់កាតព្វកិច្ចផ្លូវច្បាប់ទេ បើសិន ជាបានកំណត់តាំងពីការចាប់ផ្តើមដំណើរការដំបូង។

នៅក្នុងប្រទេសកម្ពុជា សង្គមស៊ីវិល និងអង្គភាពអាជីវកម្មមួយចំនួន មានកាតព្វកិច្ចក្នុងការផ្តល់សេវាកម្ម សម្រាប់ដោះស្រាយវិវាទការងាររួម និង / ឬវិវាទពាណិជ្ជកម្មក្រៅប្រព័ន្ធតុលាការ។ ឧទាហរណ៍ក្រុមប្រឹក្សា

---

[i] ការផ្សះផ្សាត្រូវបានអនុញ្ញាត និងមាននៅក្នុងច្បាប់ផ្សេងៗដូចជាក្រមនីតិវិធីរដ្ឋប្បវេណីសម្រាប់រឿងរដ្ឋប្បវេណី - សូមមើលក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៩៧ ច្បាប់ការងារ (វិវាទការងារ) - សូមមើលច្បាប់ការងារ មាត្រា ៣០០-៣០១ និង ៣០៣ (១៩៩៧) ច្បាប់ និងបទប្បញ្ញត្តិស្តីពីដីធ្លី (វិវាទដីធ្លី) សូមមើលឃើញអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី មាត្រា ៧-១១ (២០០២) និងព្រះរាជក្រឹត្យស្តីពីការបង្កើតអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី មាត្រា៣ និង១៥ (២០០៦) ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលក្រុមប្រឹក្សា ឃុំ សង្កាត់ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ខណ្ឌ ក្រុង និងស្រុក (ជម្លោះក្នុងមូលដ្ឋាន) ជាដើម [6]។

អាជ្ញាកណ្តាលកម្ពុជា (AC) បានបង្កើតឡើងដោយប្រកាសលេខ ០៩៩ ដែលចេញថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៤ សម្រាប់ការដោះស្រាយវិវាទការងាររួម។ ក្រុមប្រឹក្សានេះមានជំនួយផ្នែករដ្ឋបាលពីមូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល និងក្រសួងការងារ ហើយជំនួយខាងបច្ចេកទេសពីអង្គការពលកម្មអន្តរជាតិ (ILO)[12]។ ក្រុមប្រឹក្សានេះមានការទទួលស្គាល់ និងទទួលជោគជ័យក្នុងការបំពេញភារកិច្ចរបស់ខ្លួន ដោយសារឯករាជ្យភាព ដែលស្ថាប័នមាន។ គិតត្រឹមឆ្នាំ ២០១៦ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានដោះស្រាយករណីវិវាទចំនួន ២,៦៥៦ ករណី [13]។ ករណីវិវាទការងារដែលបានដំណើរការដោះស្រាយដោយ AC កើនឡើងយ៉ាងឆាប់រហ័ស ដែលពីមុនធ្លាប់តែមានចំនួន ៥ ករណី ប៉ុន្តែនៅឆ្នាំ ២០១៩ កើនឡើងពី ១១-១២ ករណីជារៀងរាល់ខែ [14]។

មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មជាតិ (ម.ជ.ម) នៃប្រទេសកម្ពុជាត្រូវបានបង្កើតឡើនៅងក្នុងឆ្នាំ ២០១០ ដើម្បីផ្តល់សេវាសម្រាប់ការដោះស្រាយវិវាទពាណិជ្ជកម្មក្រៅប្រព័ន្ធតុលាការ [15]។ សេវាកម្មអាជ្ញាកណ្តាលរបស់ ម.ជ.ម មានមុខងារនៅក្នុងក្រសួងពាណិជ្ជកម្ម ដោយផ្អែកលើច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៅកម្ពុជា (២០០៦) [16] និងអនុក្រិត្យលេខ ១២៤ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មជាតិ (២០០៩) [17, 18] ។

## ៤. ទិដ្ឋភាពនៃការអនុវត្ត ADR នៅខេត្តព្រះសីហនុ និងខេត្តកោះកុង

ទោះបីជាវិវាទដីធ្លីកើតឡើងជារឿយៗក៏ដោយ មិនមានព័ត៌មាន ឬទិន្នន័យជាក់លាក់ពីដំណោះស្រាយវិវាទដីធ្លីក្រៅប្រព័ន្ធតុលាការនៅក្នុងខេត្តទាំងពីរនេះទេ។ សម្រាប់ការសិក្សានេះ ទិន្ន័យ និងប្រភេទនៃវិវាទដែល កើតក្នុងខេត្តទាំងពីរ អាចយកបានពីទិន្ន័យឃុំ សង្កាត់ក្នុងឆ្នាំ ២០១៧ (តារាងទី ១)។ ទិន្នន័យវិវាទទាំងនោះត្រូវបានកត់ត្រាទុកដោយក្រុមប្រឹក្សាឃុំ សង្កាត់ និងចងក្រងជាប្រព័ន្ធទិន្ន័យឃុំ សង្កាត់ថ្នាក់ជាតិ ដោយក្រសួងផែនការ សម្រាប់ការត្រួតពិនិត្យ ប៉ុន្តែមិនបញ្ជាក់ពីការប្រើ ADR នុះទេ។ ទោះជាយ៉ាងណាក៏ដោយ ទិន្ន័យទាំងនោះបង្ហាញពីចំនួនវិវាទដែលបានកើតឡើងនៅក្នុងស្រុកនៃខេត្តនីមួយៗ អាចជាបន្ទុកការងារអាជ្ញាធរមូល- ដ្ឋាន។ ទាក់ទងនឹងបញ្ហានេះអាជ្ញាធរមូលដ្ឋានស្រុកស្រែអំបិល និងស្រុកបុទុមសាគរនៅក្នុងខេត្តកោះកុង ហើយនឹងស្រុកព្រះសីហនុ និងស្រុកព្រៃនប់នៅក្នុងខេត្តព្រះសីហនុអាចចែករំលែកបទពិសោធន៍នៃ ADR ។ ឧទាហរណ៍ដូចជាទិន្ន័យនៃវិវាទដៃធ្លីនៅក្នុងស្រុកទាំងនោះមានកើនឡើងច្រើនជាងគេ នៅចន្លោះពីឆ្នាំ២០០៦ និង ២០១៧ (ឧបសម្ព័ន្ធ១)។

*តារាង 1៖ ករណីវិវាទតាមបណ្ដាស្រុកនានាក្នុងខេត្តកោះកុង និងខេត្តព្រះសីហនុ ក្នុងឆ្នាំ ២០១៧*

| | វិវាទដីធ្លី | ព្រហ្មទណ្ឌ | បណ្ដឹងរដ្ឋប្បវេណី | គ្រួសារកើតមានអំពើហិង្សាក្នុងគ្រួសារ | ចោរកម្ម | សរុប |
|---|---|---|---|---|---|---|
| **ខេត្តកោះកុង** | **៩០** | **៣៥** | **១១៩** | **១២៩** | **៤៧** | **៤២០** |
| ***បូទុមសាគរ*** | ***២០*** | ***៤*** | ***៤៣*** | ***១៤*** | ***១២*** | ***៩៣*** |
| កោះកុង | ២ | ០ | ៦ | ៨ | ០ | ១៦ |
| ខេមរៈភូមិន្ទ | ៥ | ១៥ | ១៤ | ១៦ | ៦ | ៥៦ |
| គីរីសាគរ | ៧ | ៤ | ១ | ៥ | ០ | ១៧ |
| មណ្ឌលសីមា | ០ | ៦ | ៣ | ១២ | ០ | ២១ |
| ***ស្រែអំបិល*** | ***៥៦*** | ***៥*** | ***៤៩*** | ***៦៧*** | ***២៧*** | ***២០៤*** |
| ថ្មបាំង | ០ | ១ | ៣ | ៧ | ២ | ១៣ |
| **ខេត្តព្រះសីហនុ** | **៣៣៥** | **៧៥** | **៣៥០** | **១៧៣** | **១៥៩** | **១០៩២** |
| កំពុងសីលា | ១១ | ១ | ២៥ | ១៣ | ៤១ | ៩១ |
| ***ព្រះសីហនុ*** | ***២២២*** | ***៤១*** | ***១៩៣*** | ***៨២*** | ***៨៧*** | ***៦២៥*** |
| ***ព្រៃនប់*** | ***៩២*** | ***៣២*** | ***១១៥*** | ***៧២*** | ***២៦*** | ***៣៣៧*** |
| ស្ទឹងហាវ | ១០ | ១ | ១៧ | ៦ | ៥ | ៣៩ |

*ប្រភព៖ តួរលេខ ឃុំ សង្កាត់ ឆ្នាំ ២០១៧*

ផ្អែកលើប្រកាសលេខ ៨៥ រ.ប.ក/ក្រសួងយុត្តិធម៌/ក្រសួងមហាផ្ទៃ/២០០៦ នៅក្នុងឆ្នាំ ២០០៦ ក្រសួងយុត្តិធម៌ និងក្រសួងមហាផ្ទៃបានរួមគ្នាបង្កើតមជ្ឈមណ្ឌលសេវាកម្មច្បាប់ចំនួន ២០ នៅក្រុង / ស្រុក / ឃុំ សម្រាប់ ADR ។ កិច្ចខិតខំប្រឹងប្រែងរួមគ្នានេះគឺដើម្បីកាត់បន្ថយភាពជាប់គាំងនៃការដោះស្រាយរឿងក្តីនៅសាលាដំបូងខេត្ត និងដើម្បីពន្លឿនការដោះស្រាយវិវាទសម្រាប់អ្នកក្រីក្រ។ ផ្អែកលើបទពិសោធន៍ជាមេរៀនដែលបានមកពីយន្តការ ADR នេះ ក្រសួងយុត្តិធម៌បន្តដំណើរការមជ្ឈមណ្ឌលទាំង ២០ និងបានបង្កើតមជ្ឈមណ្ឌលចំនួន ៣១ នៅក្នុងក្រុង / ស្រុក និងគណៈកម្មាធិការដោះស្រាយវិវាទថ្នាក់ ឃុំ សង្កាត់ចំនួន ៥៦ កន្លែងថែមទៀត។ មុខងាររបស់មជ្ឈមណ្ឌលនៅក្នុងខេត្តទាំងពីរនោះ គួរជាគោលដៅនៃដំណើរទស្សនៈកិច្ចពិគ្រោះយោបល់របស់គណៈកម្មការ [17]។ ដូចគ្នាទៅនឹងខេត្តដ៏ទៃទៀតដែរ យន្តការទាំងបួនដែលប្រើសម្រាប់ដោះស្រាយវិវាទ មុនចូលដល់ការដោះស្រាយនៅតុលាការ រួមមាន៖ ១). ក្រុមប្រឹក្សាឃុំ ២). គណៈកម្មការសុរិយោដី ៣). គណៈកម្មការរដ្ឋបាល និង ៤). អាជ្ញាធរជាតិសម្រាប់ការដោះស្រាយវិវាទដីធ្លី [19]។

**គុណសម្បត្តិ ADR**

នៅក្នុងប្រទេសកម្ពុជា ADR អាចមានគុណសម្បត្តិជាច្រើនជាងប្រព័ន្ធតុលាការ ដូចជា៖ ១). មានតម្លៃថោកជាង និងចំណាយពេលតិចជាងក្នុងការដោះស្រាយរឿងក្តីនៅតុលាការ និង ២). អាចឲ្យភាគីវិវាទជៀសផុតពីដំណើរការតុលាការ ដែលជារឿយៗប្រជាជនតែងតែមិនទុកចិត្ត និងមិនជឿលើការឆ្លើយតបនៃដំណើរការស្មុគ្រស្មាញរបស់តុលាការ។

**គុណវិបត្តិ ADR**

ដំណើរការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ហាក់ដូចជាមានលទ្ធផលល្អក្នុងករណីដែលភាគីវិវាទមានស្ថានភាពសេដ្ឋកិច្ច និងសង្គម ដូច ឬស្រដៀងគ្នា ដោយមិនមានទទួលឥទ្ធិពលពីភាគីទីបី។ ADR ក៏ដំណើរការបានល្អផងដែរនៅពេលដែលភាគីវិវាទស្មគ្រ័ចិត្តយល់ព្រមប្រើ ADR ជាវិធីសាស្ត្រក្នុងការដោះស្រាយវិវាទ។ ការជ្រើសរើសយកយន្តការ ADR សម្រាប់ដោះស្រាយវិវាទ គឺអាស្រ័យលើលទ្ធភាពនៃភាគីវិវាទ។ គូរភាគីម្ខាងទៀតនឹងមិនទទួលយកនូវលទ្ធផលនៃដំណោះស្រាយតាមរយៈ ADR ទេ។ ប្រការនេះអាចនាំឲ្យមានវិបាកលើហិរញ្ញវត្ថុធ្ងន់ធ្ងរ ចំពោះឱកាសអាជីវកម្មនាពេលអនាគត។

## ៥. សេចក្តីសន្និដ្ឋាន

ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការមិនមែនជារឿងថ្មីនៅកម្ពុជាទេ។ ការដោះស្រាយវិវាទនេះត្រូវបានគេស្គាល់ថាជាដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ (ADR)។ ហើយត្រូវបានអនុញ្ញាតិដោយច្បាប់ជាមធ្យោបាយដោះស្រាយក្រៅប្រព័ន្ធតុលាការនឹងធ្វើឲ្យប្រសើរឡើងនូវសិទ្ធិទទួលបានយុត្តិធម៌សម្រាប់មនុស្សទាំងអស់នៅក្នុងប្រទេសកម្ពុជា។ គុណសម្បត្តិរបស់ ADR គឺ ភាគីវិវាទអាចជ្រើសរើសការដោះស្រាយបានទាំងការចរចារ សន្ធានកម្ម ការផ្សះផ្សា ឬមជ្ឈតកម្ម ស្របតាមលក្ខណៈនៃវិវាទ និងសមត្ថភាពការដោះស្រាយវិវាទរបស់ពួកគេ។ រដ្ឋាភិបាលបានបង្កើតឡើងវិញនូវគំនិតនេះជាផ្នែកមួយនៃយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងយុត្តិធម៌ដើម្បីបង្កើតយន្តការមួយចំនួននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដើម្បីដោះស្រាយវិវាទក្នុង គ្រួសារ ដីធ្លី ការងារ និងបញ្ហាពាណិជ្ជកម្ម។ ទោះបីមិនមានទិន្នន័យឬព័ត៌មានជាក់លាក់ពីប្រព័ន្ធ ADR ដែលត្រូវបានអនុវត្តនៅខេត្តកោះកុង និងខេត្តព្រះសីហនុក៏ដោយ ក៏រដ្ឋបាលមូលដ្ឋានដែលមានគណៈកម្មាដោះស្រាយវិវាទថ្នាក់ឃុំ គួរតែមានបទពិសោធន៍ទាក់ទងនឹងការដោះស្រាយវិវាទដែលអាចចែករំលែកដល់ក្រុមការងារ។

*ឧបសម្ព័ន្ធ 1៖ រំលោភដីធ្លី តាមបណ្តាស្រុក នៅក្នុងខេត្ត កោះកុង និង ព្រះសីហនុ ២០០៦-២០១៧*

| | ២០០៦ | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៦ | ២០១៧ |
|---|---|---|---|---|---|---|---|---|
| **ខេត្តកោះកុង** | **៤៤៨** | **៣៤៤** | **១៨១** | **១៤៧** | **១០២** | **៩០** | **៨៥** | **៩០** |
| ***បុទមសាគរ*** | ១៦១ | ៥១ | ៤៩ | ៩៧ | ៣៣ | ២៣ | ២៥ | ២០ |
| កោះកុង | ៣៤ | ៣ | ១២ | ១២ | ៩ | ១ | ២ | ២ |
| ខេមរៈភូមិន្ទ | ២៣ | ១៧ | ៦ | ៤ | ៩ | ១៣ | ១៣ | ៥ |
| គីរីសាគរ | ៨ | ១៩៣ | ១២ | ២ | ៧ | ១៣ | ២ | ៧ |
| មណ្ឌលសីមា | ២៤ | ២ | ៤ | ១ | ៦ | ៥ | ១ | ០ |
| ***ស្រែអំបិល*** | ១៧០ | ៦៨ | ៩៥ | ១៧ | ២១ | ២២ | ២៨ | ៥៦ |
| ថ្មបាំង | ២៨ | ១០ | ៣ | ១៤ | ១៧ | ១៣ | ១៤ | ០ |
| **ខេត្តព្រះសីហនុ** | **៥២៣** | **៣៤១** | **២០៥** | **១៥៦** | **២៩១** | **១២១** | **២០៩** | **៣៣៥** |
| កំពុងសីលា | ៩៩ | ១៣ | ១៤ | ១២ | ១០ | ៧ | ១៦ | ១១ |
| ***ព្រះសីហនុ*** | ១០៩ | ១០៦ | ៤៩ | ៤២ | ៣៦ | ៤៩ | ១០៩ | ២២២ |
| ***ព្រៃនប់*** | ២៧៨ | ២១៣ | ១៣៣ | ៩៧ | ២៤២ | ៦២ | ៦៩ | ៩២ |
| ស្ទឹងហាវ | ៣៧ | ៩ | ៩ | ៥ | ៣ | ៣ | ១៥ | ១០ |

*ប្រភព៖ តួរលេខ ឃុំ សង្កាត់ ឆ្នាំ ២០០៦-២០១៧*

# ឯកសារយោង


1. CLEC. (2012). National Consultation Workshop on Alternative Dispute resolution Practice in Cambodia. In, Imperial Garden Villa & Hotel: CLEC.Available at.: http://www.clec.org.kh/proact.php?actID=60&pID=3#.XV-ad3sxXIU [Accessed 23 Aug. 2019].
2. Find Law. (n.d). *What is Alternative Dispute Resolution?* [Online]. Find Law. Available at: https://hirealawyer.findlaw.com/choosing-the-right-lawyer/alternative-dispute-resolution.html [Accessed 23 Aug. 2019].
3. Pailler, S.,Naidoo, R.,Burgess, N., et al. (2015). Impacts of Community-Based Natural Resource Management on Wealth, Food Security and Child Health in Tanzania. *PLoS ONE* [online] 10(7). Available at: https://doi.org/10.1371/journal.pone.0133252 [Accessed 2 Sep. 2019].
4. Austermiller, S. (2010). *Alternative Dispute Resolution: Cambodia: A Textbook of Essential Concepts,* Phnom Penh, Cambodia, A publication of the American Bar Association's Rule of Law Initiative, p. 3.
5. IFC,The World Bank Group and MPDF. (2005). *Alternative Dispute Resolution:What it is, and why it is relevant to Cambodia.* [online] Phnom Penh, Cambodia: MPDF, Available at: http://documents.worldbank.org/curated/en/815321468231847217/pdf/368240Alternat1on0BIB91Cam11PUBLIC1.pdf [Accessed 23 Aug. 2019].
6. CAJC. (2017). *Overview of Cambodian Alternative Dispute Resolution System* [Online]. Phnom Penh, Cambodia: CAJC. Available at: https://cacj-ajp.org/web/cambodia/overview-of-cambodian-alternative-dispute-resolution-system [Accessed 23 Aug. 2019].
7. Zahidul, I. (2013). Legal Enforceability of ADR Agreement. *International Journal of Business and Management Invention,* 2(1). Available at: https://www.ijbmi.org/papers/Vol(2)1/Version_2/E214043.pdf [Accessed 23 Aug. 2019].
8. Law on the investment of the Kingdom of Cambodia (1994,August 4) National Assembly of Cambodia. Available at: https://www.wto.org/english/thewto_e/acc_e/khm_e/WTACCKHM3A3_LEG_45.pdf [Accessed 02 Sep. 2019].
9. International Finance Corporation's Mekong Private Sector Development Facility (IFC-MPDF) and The Asia Foundation. (2007). *The Provincial Business Environment Scorecard in Cambodia: A Measure of Economic Governance and Regulatory Policy.* Phnom Penh, Cambodia IFC-MPDF and The Asia Foundation, p. 40. Available at: https://sites.duke.edu/malesky/files/2014/07/Scorecard-in-Cambodia-2006.pdf [Accessed 30 Aug. 2019].
10. International Arbitration Attorney (IAA). (n.d). *International Arbitration Resources* [Online]. IAA. Available at: https://www.international-arbitration-attorney.com/ [Accessed 09 Sep. 2019].
11. The Abitration Council. (n.d). *History, role and function of abitration council* [Online]. Phnom Penh, Cambodia: The Abitration Council. Available at: http://www.arbitrationcouncil.org/en/about_us/arbitration_council/our_role [Accessed 22 Aug. 2019].
12. AC. (n.d). *The Arbitration Council* [Online]. Phnom Penh, Cambodia: The Arbiration Council. Available at: https://www.arbitrationcouncil.org/about-ac/the-arbitration-council/ [Accessed 26 Aug. 2019].

13. Arbitration Council Foundation (ACF). (2016). *The Arbitration Council - Annual Report 2016.* Phnom Penh, Cambodia: ACF, p.6. Available at: https://www.arbitrationcouncil.org/download/annual-report-2016/?wpdmdl=2841&refresh=5d63abc9ee8ed1566813129 [Accessed 26 Aug. 2019].
14. Voun, D. (2019). Sweden government grants $268,000 for arbitration work. . *The Phnom Penh Post*, [online], Available at: https://www.phnompenhpost.com/national/sweden-government-grants-268000-arbitration-work [Accessed 26 Aug. 2019].
15. EuroCham Cambodia. (2019). *EuroCham elected to the NCAC board* [Online]. Phnom Penh, Cambodia: EuroCham Cambodia. Available at: http://www.eurocham-cambodia.org/post/604/EuroCham-elected-to-the-NCAC-Board [Accessed 26 Aug. 2019].
16. The commercial arbitration law of the Kingdom of Cambodia (2006,March 6th) The National Assembly. . Available at: http://www.cambodiaip.gov.kh/DocResources/372a361b-7a97-44b3-9810-79e5e6ea85f4_c786a043-b88d-4f64-9429-60a330efdc5f-en.pdf [Accessed 30 Aug. 2019].
17. National Commercial Arbitration Centre. (2018). Phnom Penh, Cambodia: NCAC. Available at: https://www.ncac.org.kh/page/73-Arbitration-Services [Accessed 22 Aug. 2019].
18. Royal Government of Cambodia (2006). The commercial arbitration law Phnom Penh, Cambodia: National Assembly of Cambodia.
19. Hean, S. (2015). *A study on land disputes in four provinces of Cambodia: mapping, impacts, and possible solutions.* [online] Cambodia: The NGO Forum on Cambodia, Available at: http://ngoforum.org.kh/files/5308155d9421e8c8436b13d783eef490-Report--Study-on-Land-Disputes-in-Four-Provinces-of-Cambodia-Eng.pdf [Accessed 4 sep. 2019].